រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧០ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត សម្រាប់អាណត្តិទី៣

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម /១២០៦/០៣៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជា

- យោងតាមសំណើរបស់ទេសាភិបាលធនាគារជាតិ នៃកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំង សមាសភាពសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត សម្រាប់អាណត្តិទី៣ បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

១.- ឯកឧត្តម ជុំ គឹមឡេង តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២.- ឯកឧត្តម ង៉ែម ថុន តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា

៣.- លោក ឡាយ ម៉េងស៊ុន តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច

៤.- លោកស្រី ម៉ៅ សុន តំណាងឱ្យបុគ្គលិកធនាគារកណ្តាល

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧៦ អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយ ឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១: តែងតាំងលោក **នាយ សុខន** អតីតអគ្គកុងស៊ុល នៃស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន ជា**ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ** នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយ ឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១: តែងតាំង លោកស្រី **យស់ ម៉ាណារ៉ា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាមេរិក ជាប្រធាន**នាយកដ្ឋានអាមេរិក** នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ. បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សំរេច

មាត្រា ១ : តែងតាំងលោក **ឈុន ម៉ុនលី** បច្ចុប្បន្នអធិការនៃអគ្គាធិការដ្ឋាន ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងបរិស្ថាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន-ពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានសំរេចចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយ ឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១: តែងតាំង លោក **ជុំ សុន្ទរី** អតីតឯកអគ្គរាជទូតកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី ជា**ប្រធាននាយកដ្ឋានបុគ្គលិក** នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយ ឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១: ផ្លាស់ លោក **ហែម ហេង** បច្ចុប្បន្នប្រធាននាយកដ្ឋាន ព័ត៌មាននិងឯកសារ ជា**ប្រធាននាយកដ្ឋានអាស៊ី ទី ២** នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៦៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/ ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈ ដោយ ឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១: ផ្លាស់ លោកស្រី **រស់ ស៊ីម៉ារ៉ា** បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ីទី ២ ជា**ប្រធាននាយកដ្ឋានព័ត៌មាននិងឯកសារ** នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ១៩០ សហវ.ប្រក.

ប្រកាស

ស្តីពី

ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៩ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ ឆ្នាំ២០០៧ ។

សម្រេច :

ប្រការ១.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ត្រូវប្រមូលចាប់ពីថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ។

ប្រការ២.- ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងបង្ហាញ និង ប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៦ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូននិងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ រួចហើយ ។

ប្រការ៣.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០០៦ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ ២០០៦ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ។

ប្រការ៤.- ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ ២០០៦ រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ក្រុងនៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ ២០០៦ ។

ប្រការ៥.- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

ប្រការ៦.- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះនេះត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យ របស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ប្រការ៧.- ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណសំគាល់មួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទក្រដាសពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺព្រាំពីរពណ៌ ដោយឡែកសំរាប់បង្កាន់ដៃបង់ពន្ធលើរថយន្ត មានបន្ថែមអក្សរ សហវ និងមានសរសេរចំនួនប្រាក់ពន្ធ ៨០.០០០រៀល ១០០.០០០រៀល ១៥០.០០០រៀល ១៨០.០០០រៀល ២០០.០០០រៀល ២៥០.០០០រៀល ៤៥០.០០០រៀល ៦០០.០០០រៀល ៧៥០.០០០រៀល ៨០០.០០០រៀល ១.០០០.០០០រៀល នៅពីក្រោម។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាទុកកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច

និងទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ ២០០៨ ។

ប្រការ៨.- សំរាប់ឆ្នាំ ២០០៧ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទមានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម :

១.ប័ណ្ណរាងរង្វង់មូល :

នៅខាងលើបំផុតនៃប័ណ្ណមានអក្សរ"ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលមានលេខ "២០០៧" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធរថយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធរថយន្ត" មានសរសេរចំនួនប្រាក់ពន្ធ។ ខាងក្រោមចំនួនប្រាក់ពន្ធ មានសរសេរលេខរៀងនៃប័ណ្ណនីមួយៗ ។ នៅផ្នែកខាងមុខប័ណ្ណ មានបិទក្រដាស ពណ៌ទឹកប្រាក់ រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ និងមានពន្លឺប្រាំពីរពណ៌ ដោយឡែកសំរាប់រថយន្តមានបន្ថែមអក្សរ សហវ និង មានសរសេរចំនួនប្រាក់ពន្ធពី ៨០,០០០រៀល ដល់ ១,០០០,០០០រៀល។

ប័ណ្ណរាងរង្វង់មូលនេះមាន ១២ ពណ៌គឺ :

- ប័ណ្ណពណ៌ត្រួយចេក ប្រើសំរាប់ :
  - + ត្រាក់ទ័រមានកម្លាំង ៣៥ សេះ
  - + ត្រាក់ទ័រមានកម្លាំង ៦៥ សេះ
  - + ត្រាក់ទ័រមានកម្លាំង ៨២ សេះ
- ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំងដល់ ៩ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំង ៩ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតលើស ៥ ឆ្នាំ
- ប័ណ្ណពណ៌លឿងខ្ចី ប្រើសំរាប់ :
  - + រថយន្តដឹកទំនិញដល់ ៣ តោន
  - + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
- ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :
  - + រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- ប័ណ្ណពណ៌ផ្ទៃមេឃ ប្រើសំរាប់ :
  - + រថយន្តដឹកអ្នកដំណើរទុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :
  - + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន

+ រ៉ឺម៉កសណ្តោង ដល់ ១០ តោន
+ រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥
+ រថយន្តទេសចរណ៍កម្លាំងលើសពី ១២ សេះ ដល់ ១៧សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ

- ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :
  + រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន
  + រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន
- ប័ណ្ណពណ៌ក្រហមនិងពណ៌លឿងខ្ចី ប្រើសំរាប់ :
  + រថយន្តដឹកទំនិញលើសពី ២០ តោន
  + រ៉ឺម៉កសណ្តោងលើសពី ២០ តោន
- ប័ណ្ណពណ៌បៃតងនិងពណ៌ត្រួយចេក ប្រើសំរាប់ :
  + រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតលើសពី ៥ ឆ្នាំ
- ប័ណ្ណពណ៌លឿងទុំនិងពណ៌ផ្កាឈូក ប្រើសំរាប់ :
  + រថយន្តទេសចរណ៍កម្លាំងលើសពី ១៧ សេះ ដល់ ២៤សេះ គិតពីឆ្នាំផលិតដល់ ៥ ឆ្នាំ
- ប័ណ្ណពណ៌ខៀវនិងពណ៌ផ្ទៃមេឃ ប្រើសំរាប់ :
  + រថយន្តទេសចរណ៍កម្លាំងលើសពី ២៤សេះ ឡើងទៅ

២. ប័ណ្ណរាងត្រីកោណ :

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៧" សញ្ញារូបហង្ស និង មានអក្សរ "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធទោចក្រយានយន្ត" រាងត្រីកោណ ពណ៌ត្រួយចេក និង ពណ៌ទឹកប៊ិច មានសរសេរចំនួនប្រាក់ពន្ធ ខាងក្រោមចំនួនប្រាក់ពន្ធ មានសរសេរលេខរៀងនៃ ប័ណ្ណនីមួយៗ ។ ដោយឡែកប័ណ្ណរាងត្រីកោណពណ៌ស ពុំមានសរសេរចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងត្រីកោណនេះមាន ៣ ពណ៌គឺ :

- ប័ណ្ណពណ៌ត្រួយចេក ប្រើសំរាប់ :
  + ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ សម³
- ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :
  + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០សម³ ទៅ ១២៥ សម³
- ប័ណ្ណពណ៌ស ប្រើសំរាប់ :
  + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ សម³ ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧.៥០០ រៀល
  + ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ ដែលមានទឹកប្រាក់ពន្ធចំនួន ១៥.០០០ រៀល

៣. ប័ណ្ណរាងអដ្ឋកោណ :

នៅខាងលើបំផុតមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា" ។ ខាងក្រោមបំផុតមានអក្សរ "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។ នៅកណ្តាលប័ណ្ណមានលេខ "២០០៧" សញ្ញារូបហង្ស និងមានអក្សរ "ប័ណ្ណបង់ពន្ធជលយាន" កាត់ពាក់កណ្តាលសញ្ញារូបហង្ស និងត្រួតលើលេខ "២០០៧" ។ ខាងក្រោម "ប័ណ្ណបង់ពន្ធជលយាន" មានលេខរៀងនៃប័ណ្ណនីមួយៗ។ ប័ណ្ណរាងអដ្ឋកោណនេះ ពុំមានសរសេរចំនួនប្រាក់ពន្ធទេ ។

ប័ណ្ណរាងអដ្ឋកោណនេះមាន ៣ ពណ៌គឺ :

- ប័ណ្ណពណ៌ត្រួយចេក ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛
- ប័ណ្ណពណ៌ទឹកប៊ិច ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛
- ប័ណ្ណពណ៌ស ប្រើសំរាប់ :
  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

ប្រការ៩.- ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុបដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក(ទំនិញ-មនុស្ស)។

- ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០.០០០៛ ។
- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០.០០០៛ ។
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛ ។
- និងរ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០.០០០៛ ។

ប្រការ១០.- យានយន្តគ្រប់ប្រភេទដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៦ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះត្រូវកំណត់ឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៦ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ ២០០៧ ។

ប្រការ១១.- ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ នេះតទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណាដែលមិនបានមកបង់ពន្ធសំរាប់ឆ្នាំ ២០០៧ ដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធខេត្ត-ក្រុង នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៧ នេះ ។

ការត្រួតពិនិត្យនឹងត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយក្នុងភូមិ ឃុំ សង្កាត់ .... និង ទីចំណតនានា ។

ប្រការ១២.- ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

(តារាងឧបសម្ព័ន្ធទី I)

ភ្ជាប់ជាមួយប្រកាសលេខ ១៩០ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកតា: រៀល

ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ	អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង	
. រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមុនស្ស)] :		
+ ដល់ ៣ តោន	150 000	
+ លើសពី ៣ តោន ដល់ ១០ តោន	250 000	
+ លើសពី ១០ តោន ដល់ ២០ តោន	450 000	
+ លើសពី ២០ តោន	750 000	
. រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) :		
+ ដល់ ១០ តោន	250 000	
+ លើសពី ១០ តោន ដល់ ២០ តោន	450 000	
+ លើសពី ២០ តោន	750 000	
- រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី	250 000	
- រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥ កៅអី	200 000	
- រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី	150 000	
. រថយន្តទេសចរណ៍ គ្រប់ប្រភេទ	គិតពីឆ្នាំផលិត	
	ដល់ ៥ ឆ្នាំ	លើសពី ៥ ឆ្នាំ
+ កម្លាំងដល់ ៩ សេះ	100 000	80 000
+ កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ	150 000	100 000
+ កម្លាំងលើសពី ១២ សេះ ដល់ ១៧ សេះ	250 000	180 000
+ កម្លាំងលើសពី ១៧ សេះ ដល់ ២៤ សេះ	800 000	600 000

+ កម្លាំងលើសពី ២៤ សេះ ឡើងទៅ	1 000 000
- ត្រាក់ទ័រកម្លាំង ៨២ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល	50 000
- ត្រាក់ទ័រកម្លាំង ៦៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល	40 000
- ត្រាក់ទ័រកម្លាំង ៣៥ សេះ និង គ្រឿងចក្រប្រហាក់ប្រហែល	30 000
ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ	**កំរិតប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង**
- ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម³	3 000
- ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ ស.ម³ ដល់ ១២៥ ស.ម³	4 500
- ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម³ ឡើងទៅ	7 500
- ត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ	15 000
<u>ជលយាន ឬជលយានយន្តផ្លូវទន្លេ</u> :	
- ជលយានដឹកទំនិញ :	
+ ដល់ ៣ តោន	50 000
+ លើសពី ៣ តោន ដល់ ១០ តោន	100 000
+ លើសពី ១០ តោន ដល់ ២០ តោន	200 000
+លើសពី ២០ តោន	300 000
- កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ	100 000
- កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ	200 000
- កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ	300 000
- កប៉ាល់សណ្តោងមានកំលាំងដល់ ៥០ សេះ	20 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ	30 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ	50 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ	60 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ	180 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ឡើងទៅ	300 000
- កាណូតនេសាទមានកំលាំងដល់ ៥០ សេះ	10 000
- កាណូតនេសាទមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ	20 000
- កាណូតនេសាទមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ	30 000
- ទូកម៉ាស៊ីនចំហៀង " ជើងបង្គង "	10 000
- អូប៊័រមានកំលាំងដល់ ២៥ សេះ	150 000
- អូប៊័រមានកំលាំងលើសពី ២៥ សេះ ដល់ ៤០ សេះ	200 000
- អូប៊័រមានកំលាំងលើសពី ៤០ សេះ ដល់ ៨០ សេះ	300 000
- អូប៊័រមានកំលាំងលើសពី ៨០ សេះ ដល់ ២០០ សេះ	400 000

- អូប៉រមានកំលាំងលើសពី ២០០ សេះ ឡើងទៅ	500 000
<u>**ជលយាន ឬជលយានយន្តផ្លូវសមុទ្រ**</u> :	
- ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ	100 000
- ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ	150 000
- ទូកដឹកទំនិញដល់ ១០០ តោន	200 000
- ទូកនេសាទដែលមានកំលាំងសេះដល់ ៩ សេះ	10 000
- ទូកនេសាទដែលមានកំលាំងសេះពី ១០ សេះ ដល់ ២០ សេះ	15 000
- ទូកនេសាទដែលមានកំលាំងសេះពី ២១ សេះ ដល់ ៤០ សេះ	25 000
- ទូកនេសាទដែលមានកំលាំងសេះពី ៤១ សេះ ដល់ ៨០ សេះ	50 000

ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ	អត្រាប្រាក់ពន្ធសំរាប់ ១ ឆ្នាំក្នុងមួយគ្រឿង
- ទូកនេសាទដែលមានកំលាំងសេះពី ៨១ សេះ ដល់ ១៥០ សេះ	70 000
- ទូកនេសាទដែលមានកំលាំងសេះពី ១៥១ សេះ ឡើងទៅ	100 000
- ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេះ	10 000
- ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ១៣ សេះ ដល់ ៥០ សេះ	20 000
- ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ពី ៥១ សេះ ឡើងទៅ	50 000
- កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន	300 000
- កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន	750 000
- កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ	1 200 000
- កប៉ាល់នេសាទមានកំលាំងដល់ ១៥០ សេះ	300 000
- កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ	400 000
- កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ	600 000
- កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ	1 200 000
- កប៉ាល់សណ្តោងមានកំលាំងដល់ ២៥០ សេះ	200 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ	400 000
- កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ	600 000

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ .... សហវ.........

ឧបសម្ព័ន្ធកំណត់កំលាំងសេះរបស់រថយន្តទេសចរណ៍
(តារាងឧបសម្ព័ន្ធទី II)

ភ្ជាប់ជាមួយប្រកាសលេខ ១៩០ សហវ.ប្រក.ថ្ងៃទី ២៦ ខែ មិនា. ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ល.រ	រថយន្តទេសចរណ៍ដែលប្រើប្រាស់ថាមពលសាំង ឬ មាហ្សូត	ចំនួន CC "វ៉ូលូម"	កំលាំងគិតជាសេះ	ប្រាក់ពន្ធត្រូវបង់		សេចក្តីផ្សេងៗ
				គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ	គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ	
១	រថយន្តទេសចរណ៍	ដល់ ១ ៥០០ CC	ដល់ ៩ សេះ	១០០ ០០០	៨០ ០០០	និយមហៅ ១.៥
២	រថយន្តទេសចរណ៍	លើសពី ១ ៥០០ CC ដល់ ២ ០០០ CC	លើសពី ៩ សេះ ដល់ ១២ សេះ	១៥០ ០០០	១០០ ០០០	និយមហៅ ១.៦ ដល់ ២
៣	រថយន្តទេសចរណ៍	លើសពី ២ ០០០ CC ដល់ ២ ៥០០ CC	លើសពី ១២ សេះ ដល់ ១៧ សេះ	២៥០ ០០០	១៨០ ០០០	និយមហៅ ២.២ ដល់ ២.៥
៤	រថយន្តទេសចរណ៍	លើសពី ២ ៥០០ CC ដល់ ៤ ០០០ CC	លើសពី ១៧ សេះ ដល់ ២៤ សេះ	៨០០ ០០០	៦០០ ០០០	និយមហៅ ៣ ដល់ ៤
៥	រថយន្តទេសចរណ៍	លើសពី ៤ ០០០ CC ឡើងទៅ	លើសពី ២៤ សេះ ឡើងទៅ	១ ០០០ ០០០		និយមហៅ លើសពី ៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៩១ សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពីគោលការណ៍ចំណាយសំរាប់អនុវត្ត
ថវិកាតាមកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា

****

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ .ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ០៧០៤ / ១២៤. ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០១/ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម/ ១២៩៩ / ១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២ /០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាស លេខ ១៤០១ សហវ.ប្រកចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីកាដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិការថវិកាទូទៅរបស់រដ្ឋ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ២០០៧

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញសារាចរលេខ ០១៦ សហវ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការណែនាំលើការអនុវត្តថវិកាឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

-អនុលោមតាមការចាំបាច់ និង ជាក់ស្តែងចំពោះមុខ

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

ប្រការ១ : ក្រសួងអប់រំ យុវជន និង កីឡា ត្រូវមានភារកិច្ចរៀបចំគំរោង ផែនការ ថវិកាតាមកម្មវិធី និង គំរោងចំណាយថវិកា ដើម្បីធានាអោយការចំណាយមានតម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាពខ្ពស់ សំដៅ លើកកំពស់គុណភាពនៃការសិក្សាអប់រំ និង បណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយសមធម៌ ជាពិសេស ដើម្បី កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ជំពូកទី ២

គោលការណ៍ចំណាយ

ប្រការ២ : គោលការណ៍ចំណាយដោយឡែក ត្រូវបានកំណត់អោយអនុវត្ត សំរាប់ ថវិកាតាមកម្មវិធី ក្នុងការអភិវឌ្ឍលើវិស័យអប់រំ ដូចខាងក្រោម :

ក- គុណភាព និងប្រសិទ្ធភាពនៃការអប់រំកុមារតូច

ផ្តល់ថវិកាសំរាប់ដំណើរការសាលាមត្តេយ្យរដ្ឋដែលមាន ៣ក្រិត ចំនួនពី ២០០.០០០រៀល-៣០០.០០០រៀល ក្នុងមួយសាលា ។ ចំនួន ៦.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា (ថ្នាក់មត្តេយ្យរដ្ឋក្រិតខ្ពស់ដែលកុមារ មានអាយុប្រាំឆ្នាំ ទោះបីសាលាមត្តេយ្យនោះស្ថិតនៅក្រោមការគ្រប់គ្រង របស់សាលាបឋមសិក្សាក៏ដោយ) សំរាប់ចំណាយលើ:

-សំភារៈមូលដ្ឋាន

-ការកែលំអបរិស្ថាន សាលា និង ថ្នាក់រៀន

-ការជួសជុលតូច (សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច)

-ចំណាយសំរាប់ទឹកស្អាត និងអនាម័យ

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក

-ចំណាយផ្សេងៗ ។

ខ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

១-ថវិកាសំរាប់ដំណើរការសាលារៀន

ផ្តល់ថវិកា ដល់គ្រប់សាលាបឋមសិក្សា ចំនួនពី ៥០០.០០០រៀល -៧០០.០០០រៀល ក្នុងមួយសាលា និងចំនួន ៧.០០០រៀល- ៨.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សាសំរាប់ចំណាយលើ :

- សំភារៈមូលដ្ឋាន
-ការជួសជុលតូច (សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច)
-ការកែលំអបរិស្ថានសាលា និងថ្នាក់រៀន
-បំណិនជីវិត (កីឡា សិល្បៈ រោងជាង គេហវិជ្ជា និង កសិកម្ម)
-ចំណាយសំរាប់ទឹកស្អាត និងអនាម័យ
-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
-ការរៀបចំឯកសារធ្វើតេស្តចុងឆ្នាំសិក្សា សំរាប់ថ្នាក់ទី ៣ និង ទី ៦
-ចំណាយផ្សេងៗ ។

២-ថវិកាសំរាប់ពង្រឹង គុណភាពរៀន និងបង្រៀន

-ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកំរងសាលារៀន(ដើមឆ្នាំ កណ្តាលឆ្នាំ និង ចុងឆ្នាំ) ចំនួន ១១ពេល ក្នុងមួយឆ្នាំសិក្សា។

-ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន ដែលបានបង្រៀនម៉ោងបន្ថែម សំរាប់ជួយសិស្ស នៅថ្ងៃព្រហស្បតិ៍ក្នុងឆ្នាំសិក្សា ចំនួន ១០.០០០រៀល ក្នុងមួយពេលក្នុងមួយនាក់ ដោយគិតទាំងអ្នកគ្រប់គ្រង បណ្ណារក្ស រោងជាង និងលេខាធិការ ។

គ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

១-ផ្តល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួនពី១.០០០.០០០រៀល-១.៥០០.០០០រៀល ក្នុងមួយសាលា ដល់គ្រប់អនុវិទ្យាល័យ និងវិទ្យាល័យ និងចំនួន ១៥.០០០រៀល - ១៨.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ ចំណាយលើ :

- សំភារៈមូលដ្ឋាន
- ការកែលំអបរិស្ថានសាលារៀន និងថ្នាក់រៀន
- ការជួសជុលតូច (សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច)

- បំណិនជីវិត (កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម)
- ការរៀបចំឯកសារ និង សំភារៈផ្សេងៗ សំរាប់ប្រលងឆមាស
- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ចំណាយផ្សេងៗ ។

២-ផ្តល់ថវិកាសំរាប់ប្រគល់រង្វាន់សិស្សពូកែប្រចាំឆ្នាំ ចំនួន ១០០.០០០រៀលក្នុងមួយថ្នាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើសំភារៈសិក្សា ។

ឃ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការរៀបចំស្តង់ដាតេស្ត ការទទួលស្គាល់កម្មវិធីសិក្សា និង មេរៀន ដោយអញ្ជើញអ្នកបច្ចេកទេសពីស្ថាប័នផ្សេង មកជួយហើយផ្តល់ជូន ១ជំនាញមាន ០២នាក់ចំនួន ១.០០០.០០០រៀល ក្នុងមួយករិត ។

ង- បន្តការអភិវឌ្ឍគ្រូបង្រៀន

១- ផ្តល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួន ៣០.០០០.០០០រៀល ក្នុងមួយសាលាដល់ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ចំនួនពី១០០.០០០រៀល- ១២០.០០០រៀលក្នុងគរុសិស្ស-និស្សិតមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើ :

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពអប់រំសីលធម៌ និង មនសិការវិជ្ជាជីវៈ
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពពលកម្មផលិត
- សកម្មភាពសិល្បៈ និង កីឡា
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ
- ចំណាយផ្សេងៗ:
    - +សំភារៈមូលដ្ឋាន
    - + ការជួសជុលតូច (សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច)
    - +ការដឹកជញ្ជូន ការផ្គត់ផ្គង់សំភារៈ ។

២ -ការរៀបចំឯកសារធ្វើតេស្ត សំរាប់វាយតម្លៃសមត្ថភាពគ្រូឧទ្ទេសត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

- ការកសាងតេស្ត	ឧបត្ថម្ភ	១០០.០០០រៀល/ ១មុខវិជ្ជា
- ការធ្វើអត្រាកំណែ	ឧបត្ថម្ភ	២០.០០០រៀល/ ១នាក់
- កំរែកែកិច្ចការ	ឧបត្ថម្ភ	២.០០០រៀល/ ១កិច្ចការ

- គណៈកម្មការបូកសរុបលទ្ធផល ឧបត្ថម្ភ ៥០.០០០រៀល/ ១នាក់
- គណៈកម្មការត្រួតពិនិត្យ ឧបត្ថម្ភ ៣០.០០០រៀល/ ១នាក់
- អ្នកធ្វើរបាយការណ៍ ឧបត្ថម្ភ ៣០.០០០រៀល/ ១នាក់

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសេចក្តីណែនាំស្តី ពីការកំណត់និយាមរៀបចំគណៈកម្មការនីមួយៗ អោយបានច្បាស់លាស់ក្នុងក៏រិតអប្បបរមា ។

ច- ចំពោះគ្រឹះស្ថាន ឬ មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដែលចប់ការគាំទ្រទាំងផ្នែកសំភារៈ និងថវិកាពីរដ្ឋាភិបាលបរទេស ឬ អង្គការអន្តរជាតិ នឹងទទួលបានការឧបត្ថម្ភថវិកាសំរាប់ដំណើរការសាលារៀន ចំនួន ៥០.០០០.០០០រៀល ក្នុងមួយសាលា និង ចំនួន ៥០០.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សំភារៈមូលដ្ឋាន
- ការជួសជុលតូច (សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច)
- សំភារៈកសិកម្ម រោងជាង និងបន្ទប់ពិសោធន៍
- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ចំណាយផ្សេងៗ ។

ឆ- គុណភាព និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា

ផ្តល់ថវិកាសំរាប់ដំណើរការមជ្ឈមណ្ឌល ឬ សាលា ចំនួន ៣០.០០០.០០០រៀល ក្នុងមួយ មជ្ឈមណ្ឌល ឬសាលា និងចំនួន ១២០.០០០រៀល ក្នុងគរុសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពបច្ចេកទេស និង ប្រកួត
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រកីឡា និង វេជ្ជសាស្ត្រកីឡា
- ចំណាយផ្សេងៗៈ
    - +សំភារៈការិយាល័យ
    - +ការជួសជុលទីលាន និង សំភារៈបច្ចេកទេសហ្វឹកហាត់
    - +ការដឹកជញ្ជូន
    - +ការផ្គត់ផ្គង់
    - +ឯកសារសំរាប់ប្រជុំ ។

8

ជ- ការពង្រីកអប់រំក្រៅម៉ោង :

ផ្តល់ថវិកាសំរាប់ដំណើរការ ថ្នាក់បំប៉នសិស្សបោះបង់ការសិក្សាចំនួនពី៥០.០០០រៀល-១០០.០០០រៀល ក្នុងមួយថ្នាក់ក្នុង ១ឆ្នាំ (ខែសីហា និងកញ្ញា) សំរាប់ចំណាយលើ : សៀវភៅ ប៊ិច ដីស ហ្វឺតសរសេរ ក្ដារខៀន ។ល ។

ឈ- គោលការណ៍រួម និងដោយឡែក សំរាប់អនុវត្តគ្រប់អង្គភាពដែលបានទទួលថវិកាតាមកម្មវិធី :

ការអនុវត្តថវិកាតាមកម្មវិធី និងការកសាងឯកសារបង្រៀន និងរៀនត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

១-គោលការណ៍រួម

- ការថតចំលងឯកសារដោយមិនប្រើសំភារៈរបស់រដ្ឋ ទូទាត់ តាមតំលៃជាក់ស្តែង

- ការវាយកុំព្យូទ័រ	ឧបត្ថម្ភ	១.៥០០រៀល	ក្នុង១ទំព័រ
- អ្នកគូររូប	ឧបត្ថម្ភ	១៦.០០០រៀល	ក្នុង១ទំព័រ
- ការបកប្រែឯកសារ	ឧបត្ថម្ភ	៤.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- អ្នកនិពន្ធ	ឧបត្ថម្ភ	១៤.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យ	ឧបត្ថម្ភ	១.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការរៀបរៀង និង ចងក្រង	ឧបត្ថម្ភ	៤.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការកែលំអមេរៀន	ឧបត្ថម្ភ	១២.០០០រៀល	ក្នុង១មេរៀន

២-គោលការណ៍ដោយឡែកសំរាប់អនុវត្ត នៅតាមគ្រឹះស្ថានឧត្តមសិក្សា

- ការបកប្រែឯកសារ	ឧបត្ថម្ភ	១២.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- អ្នកនិពន្ធ	ឧបត្ថម្ភ	២៨.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
-ការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យ	ឧបត្ថម្ភ	៤.០០០រៀល	ក្នុង១ទំព័រវាយកុំព្យូទ័រ
- ការកែលំអមេរៀន	ឧបត្ថម្ភ	២០.០០០រៀល	ក្នុង១មួយមេរៀន
- ការជួលម៉ូដែល (Model) មនុស្សពិតមកធ្វើគំរូ សំរាប់អោយនិស្សិតគូរតាម	ឧបត្ថម្ភ	២០.០០០រៀល	ក្នុង១គំរូ ក្នុង១ពេល

⊗ ចំពោះការទិញសំភារៈ និងឯកសារស្រាវជ្រាវផ្សេងៗពីបរទេស ត្រូវទូទាត់តាមសក្ខីបត្រជាក់ស្តែងតាមអត្រាប្តូរប្រាក់ជាផ្លូវការរបស់ធនាគារជាតិ (ចំពោះតែសំភារៈនិងឯកសារណាដែលគ្មានលក់លើទីផ្សារក្នុងស្រុក) ។

៥

ជំពូក ៣
ការអនុវត្តថវិកាតាមកម្មវិធី

ប្រការ ៣ : ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងផ្ទេរឥណទានថវិកាតាមកម្មវិធីជូន ទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ឥណទានថវិកានេះ អោយទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។ ចំពោះយន្តការដែលត្រូវអនុវត្តថវិកាតាមកម្មវិធីមានដូចខាងក្រោម:

-ឥណទានថវិកា សំរាប់ចំណាយដំណើរការថ្នាក់រៀន មជ្ឈមណ្ឌលសហគមន៍ សាលា គ្រឹះស្ថានសិក្សា និងការចំណាយថវិកាដែលមានគោលការណ៍កំណត់ច្បាស់លាស់ ត្រូវអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទានមួយរយភាគរយ (១០០ %) ដោយមិនគិត ១/៤ លើ ៣០ភាគរយនៃឥណទានដែលជ្រើសរើសមកបង្កើតរជ្ជទេយ្យបុរេប្រទាននេះទេ ។

- រាល់ការចំណាយថវិកាដែលពាក់ព័ន្ធទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗ ដែលមានទឹកប្រាក់ក្រោម **២០ លានរៀល** ត្រូវអនុវត្តតាមលំនាំនីតិវិធី នៃវិធីសាស្ត្រលទ្ធកម្ម "សួរថ្លៃ" ។

ប្រការ ៤ : ក្រោយពីមានប្រកាសអន្តរក្រសួង ស្ដីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងការបង្កើតរជ្ជទេយ្យបុរេប្រទានរួចមកក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំបែបបទនៃការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទានដូចខាងក្រោម :

- រដ្ឋបាលកណ្ដាល : ក្រសួងអប់រំ យុវជន និងកីឡា ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគារជាតិតែម្ដង

- ខេត្ត-ក្រុង : មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគារខេត្ត-ក្រុង តែម្ដង រួចរៀបចំបែងចែកសាច់ប្រាក់ជូនទៅ គ្រឹះស្ថានសិក្សា និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក- ខណ្ឌ ដើម្បីបន្តបើកផ្ដល់ជូនសាលារៀន ។

ប្រការ ៥ : នីតិវិធី នៃការទូទាត់រជ្ជទេយ្យបុរេប្រទានត្រូវអនុវត្តតាមបរិបថដូចខាងក្រោម:

- រដ្ឋបាលកណ្ដាល : គ្រប់អង្គភាពដែលអនុវត្តថវិកាតាមកម្មវិធីត្រូវប្រមូលសក្ខីប័ត្រចំណាយ និងលិខិតយុត្តិការ រៀបចំបោះផ្សាយអាណត្តិទូទាត់ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលអមផ្ទាល់នៅក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិពិនិត្យ និងចុះហត្ថលេខាលើអាណត្តិទូទាត់រជ្ជទេយ្យបុរេប្រទានក្នុងនាមជាអភិបាលហិរញ្ញវត្ថុ បន្ទាប់មកបញ្ជូនទៅរតនាគារជាតិ ។

8 · [illegible]

- ខេត្ត-ក្រុង :

+ថ្នាក់រៀន មជ្ឈមណ្ឌលសហគមន៍ និងសាលារៀនត្រូវរៀបចំសក្ខីប័ត្រចំណាយ និងលិខិតយុត្តិការបញ្ជូនទៅ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក - ខណ្ឌ។ ការិយាល័យអប់រំ ស្រុក-ខណ្ឌត្រូវត្រួតពិនិត្យឯកសារទាំងអស់អោយបានត្រឹមត្រូវ និងបូកសរុប រួចបញ្ជូនបន្តទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង

+គ្រឹះស្ថានសិក្សា ត្រូវរៀបចំប្រមូលសក្ខីប័ត្រចំណាយនិងលិខិតយុត្តិការបញ្ជូនទៅ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង។

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវពិនិត្យអោយបានត្រឹមត្រូវរាល់សក្ខីប័ត្រចំណាយ និងលិខិតយុត្តិការទាំងអស់ រួចរៀបចំបោះផ្សាយអាណត្តិទូទាត់ និងចុះហត្ថលេខា ដោយអាណាប័កផ្ទេរសិទ្ធិ បន្ទាប់មកបញ្ជូនអាណត្តិទូទាត់នោះ ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ពិនិត្យ និងចុះហត្ថលេខាក្នុងនាមជាអភិបាលហិរញ្ញវត្ថុ មុននឹងបញ្ជូនទៅរតនាគារខេត្ត-ក្រុង ។

ជំពូក៤

អវសានបញ្ញត្តិ

ប្រការ៦ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ ២០០៧ តទៅ។

ប្រការ៧ : រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ៨ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ច អនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ុំ_សិទ្ធិ

កន្លែងទទួល :

-អគ្គលេខាធិការព្រឹទ្ធសភា
-អគ្គលេខាធិការរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសេវនកម្មជាតិ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
 "ដើម្បីជូនជ្រាប"
-ដូចប្រការ ៨ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៧ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០៧

សេចក្តីជូនដំណឹង
ស្តីពី
ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០០៧

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជំរាបលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទមេត្តាជ្រាបថា : ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៧ ត្រូវចាប់អនុវត្តពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ។

<u>ពន្ធនេះត្រូវបានលើកលែងមិនប្រមូលចំពោះ</u> :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះជាកម្មសិទ្ធរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបំពេញនូវលិខិតប្រកាសចំនួន០២សន្លឹក តាមគំរូឯកភាពរបស់នាយកដ្ឋានពន្ធដារ ព្រមទាំងត្រូវបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ចនូវបង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៦ សំរាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ រួចហើយ ។ ក្នុងករណីបាត់បង្កាន់ដៃបញ្ជាក់ការបង់ពន្ធសំរាប់ឆ្នាំ២០០៦ ម្ចាស់មធ្យោបាយនិងយានជំនិះត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ចេញដោយរដ្ឋបាលសារពើពន្ធ នៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ឬ ប្រកាសបង់ពន្ធនៅទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៦ ដើម្បីមានការងាយស្រួលបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយគល់ប័ណ្ណបង្កាន់ដៃបង់ពន្ធឆ្នាំ២០០៦ ដែលផ្នែកពន្ធរក្សាទុក ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលពុំមានបង្កាន់ដៃបញ្ជាក់ពីការបានបង់ពន្ធឆ្នាំ២០០៦ ទេនោះ ត្រូវបង់ពន្ធសំរាប់ឆ្នាំ២០០៦ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៧។

ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនិមួយៗ ត្រូវបានទទួលប័ណ្ណបង់ពន្ធមួយសន្លឹកសំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនិមួយៗ និង បង្កាន់ដៃបង់ពន្ធមួយសន្លឹកទៀត ។ ម្ចាស់មធ្យោបាយ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

ដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវរក្សាទុកបង្កាន់ដៃបង់ពន្ធ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។

ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៧ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ តទៅ ។

ការត្រួតពិនិត្យនេះ និង ត្រូវអនុវត្តនៅតាមទីចំណតនៃមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយ ក្នុងភូមិ ឃុំ សង្កាត់ ... និង ទីចំណតនានា ។

ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់ឱ្យធ្វើចរាចរនៅក្រោយថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និង ត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធខេត្ត-ក្រុង នៅរៀងរាល់ថ្ងៃធ្វើការ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ ២០០៧ នេះ ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់យានយន្តគ្រប់ប្រភេទ មេត្តាប្រញាប់ប្រញាល់រួសរាន់អញ្ជើញទៅបង់ពន្ធនេះអោយបានមុនថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ កុំបីខាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៣៦ ១៥.ឧរ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៥៦៣ ផក.ប្រក ចុះថ្ងៃទី១៨.០៥.១៩៩៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣០៨៧/០៥ គ.វ.ក ចុះថ្ងៃទី០៧.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន លាន អ៊ីង អ៊ឹមផត & អិចផត ចុះថ្ងៃទី២០.០៤.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន លាន អ៊ីង អ៊ឹមផត & អិចផត (LEAN ING IMPORT & EXPORT CO., LTD.) តំណាងដោយ លោក LI QI សញ្ជាតិចិន អាយុ២៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G06467577 ចុះថ្ងៃទី ០២.០១.២០០៤ បង្កើតរោងចក្រ "តម្លើងម៉ូតូ " ដែលមានឈ្មោះថា " លាន អ៊ីង អ៊ឹមផត & អិចផត (LEAN ING IMPORT & EXPORT)" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិកំបូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23 211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល ១៥ថ្ងៃ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "តម្លើងម៉ូតូ " ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុន ត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ ៥៦៣ ផក.ប្រក ចុះថ្ងៃទី១៨.០៩.១៩៩២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ តម្លើងទូរទស្សន៍ និងគ្រឿងបរិក្ខារអេឡិចត្រូនិចនាំចេញ របស់ក្រុមហ៊ុន " ថាកក្រាល ខេមបូឌាអ៊ិនដាស្ទ្រីស៍ លីមីធីដ " (THAKRAL CAMBODIA INDUSTRIES LIMITED) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន លាន អ៊ឹង អ៊ិមផត & អិចផត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
